**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធនធានទឹក និងឧតុនិយម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## គម្រោងកែលម្អសន្តិសុខទឹកនៅកម្ពុជា (P176615)

# សេចក្តីសង្ខេប

*សម្រាប់*

# ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់

ពង្រាងទី១ សម្រាប់ផ្សព្វផ្សាយជាសាធារណៈ

ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២៣

រៀបចំដោយ៖ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីសង្ខេបទូទៅ

## ១. សេចក្តីណែនាំស្តីពីគម្រោង

គម្រោងកែលម្អសន្តិសុខទឹកកម្ពុជា (CWSIP, P176615) មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខទឹក និងបង្កើនផលិតភាពកសិកម្មនៅក្នុងអាងទន្លេដែលបានជ្រើសរើសនៅប្រទេសកម្ពុជា និងផ្តល់ការឆ្លើយតបជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាពក្នុងករណីមានវិបត្តិនៃភាពអាសន្ន។

គោលបំណងអភិវឌ្ឍន៍គម្រោង (PDO) នឹងត្រូវបានវាស់វែងតាមរយៈសូចនាករដូចខាងក្រោម៖

- ការបង្កើនលទ្ធភាពទឹកសម្រាប់កសិកម្ម និងការផ្គត់ផ្គង់ទឹកក្នុងស្រុកនៅក្នុងតំបន់ខ្វះខាតទឹក (MCM)
- តំបន់ផ្តល់សេវាប្រព័ន្ធធារាសាស្ត្រ ឬប្រព័ន្ធបង្ហូរ (ហិចតា)
- បង្កើនផលិតភាពកសិកម្ម (ភាគរយ)

គម្រោងនេះនឹងត្រូវបានអនុវត្តចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០៣០ តាមរយៈសកម្មភាពវិនិយោគផ្សេងៗដែលរៀបចំឡើងក្នុងផ្នែកចំនួនប្រាំនៃគម្រោង៖

- សមាសភាគ១៖ ការកសាងមូលដ្ឋានគ្រឹះសម្រាប់កែលម្អសេវាធនធានទឹក (១០លានដុល្លារអាមេរិក)
- សមាសភាគ២៖ និរន្តរភាពសេវាផ្គត់ផ្គង់ទឹក (១១០លានដុល្លារអាមេរិក)
- សមាសភាគទី៣៖ សេវាគាំទ្រជំរុញបង្កើនភាពធន់នឹងអាកាសធាតុនៃធារាសាស្ត្រកសិកម្ម (២០លានដុល្លារអាមេរិក)
- សមាសភាគ៤៖ ការគ្រប់គ្រងគម្រោង ការសម្របសម្រួល និងការត្រួតពិនិត្យ និងការវាយតម្លៃ (៥លានដុល្លារអាមេរិក)
- សមាសភាគ៥៖ សមាសភាគបម្រុងឆ្លើយតបបន្ទាន់ (CERC) (0 លានដុល្លារអាមេរិក)។

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោងនឹងរួមមាន៖

- ការកែលម្អទំនប់ ការដំឡើងទ្វារទឹកដែក និងការកែលម្អ និងស្តារប្រឡាយមេ
- ការជួសជុលទំនប់ កសាងរចនាសម្ព័ន្ធទ្វារទឹកថ្មី និងទំនប់បង្ហៀរ ការពង្រីកប្រឡាយមេ និងប្រព័ន្ធចែកចាយ
- ការស្តារឡើងវិញនូវអាងស្តុកទឹកក្រៅប្រព័ន្ធផ្លូវទឹក ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់ទឹកសម្រាប់ការពង្រីកតំបន់ដាំដុះដែលមានស្រាប់ និងបង្កើនប្រពលវប្បកម្មដំណាំ
- បង្កើតដំណើរការ O&M សម្រាប់ទំនប់ទឹក ទំនប់ស្ទាក់ទឹក និងអាងស្តុកទឹកក្រៅប្រព័ន្ធផ្លូវទឹក ដើម្បីគ្រប់គ្រងការបង្ហូរទឹកនៅរដូវប្រាំង និងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់នៅរដូវវស្សា
- គាំទ្រដល់ PDWRAM ដើម្បីត្រួតពិនិត្យលំហូរទឹក និងកម្រិតទឹកជាប្រចាំ និងដើម្បីដំណើរការទ្វារទឹក និងអាងស្តុកទឹកក្រៅប្រព័ន្ធផ្លូវទឹកប្រកបដោយប្រសិទ្ធភាពប្រចាំឆ្នាំ
- ជួយដល់កសិករក្នុងការផ្លាស់ប្តូរដំណាំប្រពលវប្បកម្មដែលប្រើប្រាស់ទឹកតិច និងដំណាំដែលមានតម្លៃខ្ពស់ជាង

- ពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និងគណៈកម្មាធិការអាងទន្លេ (RBC) យន្តការ និង មុខងារប្រតិបត្តិការប្រកបដោយនិរន្តរភាព
- ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិថ្មី/ដែលមានស្រាប់ តាមរយៈការលើកកម្ពស់ការកែលម្អគោលនយោបាយ សមាហរណកម្មវិស័យនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងគណៈកម្មាធិការអាងទន្លេ
- ការសាកល្បងនៃដំណោះស្រាយផ្អែកលើធម្មជាតិ (NbS) សម្រាប់ការគ្រប់គ្រងហានិភ័យទឹកជំនន់ និង ការគ្រប់គ្រងសំណឹកដី

## ២. គោលបំណងនៃ RPF

ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង លទ្ធកម្មដីធ្លីត្រូវបានរំពឹងទុក ទាំងលក្ខណៈអចិន្ត្រៃយ៍ និងបណ្តោះអាសន្ន ដើម្បីជួយសម្រួលដល់ការសាងសង់ប្រឡាយធារាសាស្ត្រ ផ្លូវតាមប្រឡាយ ទំនប់ប្រាំងទន្លេ និងការធ្វើឱ្យប្រសើរឡើងអាងស្តុកទឹកដែលមានស្រាប់។ កំឡុងពេលសាងសង់ នៅក្នុងតំបន់អនុគម្រោងមួយចំនួន កសិករអាចជួបប្រទះការរឹតត្បិតក្នុងការចូលទៅកាន់ប្រភពទឹកស្រោចស្រពដែលមានស្រាប់ ដោយសារប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ពុំដំណើរការ (នៅទីតាំងជាក់លាក់ណាមួយ) សម្រាប់ការស្តារឡើងវិញ។ អាស្រ័យហេតុនេះ RPF ត្រូវបានរៀបចំដើម្បីធានាថានៅពេលដែលកើតមាននូវលទ្ធកម្មដីធ្លី និងការរឹតបន្តឹងការប្រើប្រាស់ទឹកដោយសារសកម្មភាពគម្រោង ហើយផលប៉ះពាល់បែបនេះមិនអាចជៀសវាងបានដោយសារហេតុផលបច្ចេកទេស គ្រួសារដែលរងផលប៉ះពាល់នឹងត្រូវបានផ្តល់សំណងសម្រាប់ការបាត់បង់ដី ដំណាំ និងអាជីវកម្មដែលទាក់ទងនឹងដីដែលរងផលប៉ះពាល់។ ការបាត់បង់ដំណាំ/ប្រាក់ចំណូលដោយសារការរឹតបន្តឹងការប្រើប្រាស់ទឹក និងមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងពុំមែនជាហិរញ្ញវត្ថុផ្សេងទៀត ដើម្បីស្តារជីវភាពដែលទទួលរងផលប៉ះពាល់នៅក្នុងកម្រិតមុនមានគម្រោង។

RPF នេះត្រូវបានរៀបចំឡើងដោយក្រសួងធនធានទឹក និងឧតុនិយម (MoRWAM) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដោយមានការគាំទ្របច្ចេកទេសពីអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (GDR) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ RPF ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារនិតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ (SOP-LAR) របស់រាជរដ្ឋាភិបាលកម្ពុជា (RGC) និងក្របខ័ណ្ឌបរិស្ថាន និងសង្គមរបស់ធនាគារពិភពលោក (ESF របស់ WB)។ ឯកសារនេះគឺជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាព/ផ្លាស់ប្តូរនៅពេលមានតម្រូវការ និងមានការយល់ព្រមរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក។

## ៣. គោលបំណងនៃ RPF

RPF មានគោលបំណង (i) ជៀសវាងការតាំងទីលំនៅថ្មីដោយពុំស្ម័គ្រចិត្ត ឬពេលដែលមិនអាចជៀសបាន កាត់បន្ថយការតាំងទីលំនៅថ្មីដោយពុំស្ម័គ្រចិត្តដោយស្វែងរកជម្រើសនានាក្នុងការរចនាគម្រោង (ii) ជៀសវាងការបណ្តេញចេញដោយបង្ខំ និង (iii) កាត់បន្ថយផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចដែលមិនអាចជៀសវាងបានពីលទ្ធ

កម្មដីធ្លី ឬការរឹតបន្តឹងលើការប្រើប្រាស់ដីធ្លីដោយៈ (ក) ការផ្តល់សំណងទាន់ពេលវេលាសម្រាប់ការបាត់បង់ទ្រព្យសម្បត្តិក្នុងតម្លៃជំនួស និង (ខ) ជួយអ្នករងផលប៉ះពាល់ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អ ឬយ៉ាងហោចណាស់ ស្តារឡើងវិញ ជីវភាពរស់នៅ និងស្តង់ដាររស់នៅរបស់ពួកគេ តាមតម្លៃជាក់ស្តែង នៅមុនស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ ឬមុនស្ថានភាពនៃការចាប់ផ្តើមអនុវត្តគម្រោង ទៅតាមកម្រិតណាមួយខ្ពស់ជាង។

គម្រោងនេះនឹងខិតខំប្រឹងប្រែង និងវាស់វែងគ្រប់បែបយ៉ាង ដើម្បីជៀសវាងការធ្វើលទ្ធកម្មដីធ្លី តាមរយៈការជំនួសមកវិញនូវការរចនា និងការប្រើប្រាស់ដីសាធារណៈរបស់រដ្ឋ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែលពុំអាចជៀសវាងបាន តម្រូវការធ្វើលទ្ធកម្មដីធ្លីនឹងត្រូវបានបង្រួមឱ្យនៅត្រឹមអប្បបរមាតាមរយៈវិធានការ/វិធីសាស្ត្រសាងសង់។ នៅពេលដែលផលប៉ះពាល់លើដីធ្លី ទ្រព្យសម្បត្តិ និងសកម្មភាពចិញ្ចឹមជីវិតពុំអាចជៀសបាន គម្រោងនេះនឹងធានាការទូទាត់សំណងពេញលេញសម្រាប់ទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ និងសកម្មភាពបង្កើតប្រាក់ចំណូល ក៏ដូចជាការកែលម្អ ឬយ៉ាងហោចណាស់ស្តារឡើងវិញនូវជីវភាព និងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងមុនស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ។

## ៤. រចនាសម្ព័ន្ធនៃ RPF

RPF ត្រូវបានរៀបចំជា ១០ ជំពូកដែលនឹងត្រូវបានអនុវត្តដើម្បីសម្រេចបាននូវគោលបំណងនៃRPF។
• ជំពូកទី១ (សេចក្តីផ្តើម) បង្ហាញពីទិដ្ឋភាពទូទៅនៃគម្រោង រួមទាំងគោលបំណងនៃការអភិវឌ្ឍគម្រោង សមាសភាគនៃគម្រោង។
• ជំពូកទី២ (ការវាយតម្លៃនៃផលប៉ះពាល់នៃលទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់) ប៉ាន់ប្រមាណវិសាលភាពសក្តានុពលនៃការធ្វើលទ្ធកម្មដីធ្លីដោយផ្អែកលើអនុគម្រោងដែលបានកំណត់អំឡុងពេលរៀបចំគម្រោង។ ពិពណ៌នាជាសង្ខេបអំពីផលប៉ះពាល់គម្រោងសំខាន់ៗ ក៏ដូចជារបៀបដែលផលប៉ះពាល់ទាំងនេះត្រូវបានជៀសវាង កាត់បន្ថយ និងផ្តល់សំណងឱ្យ។
• ជំពូកទី៣ (ក្របខ័ណ្ឌច្បាប់) ពិពណ៌នាអំពីឯកសារច្បាប់ទាំងរបស់ធនាគារពិភពលោក (WB) និងរាជរដ្ឋាភិបាលកម្ពុជា (RGC) ហើយប្រៀបធៀបឯកសារច្បាប់ពាក់ព័ន្ធរបស់ WB និងរាជរដ្ឋាភិបាលដើម្បីកំណត់ចំណុចខ្វះខាត និងស្នើឡើងនូវវិធានសុខដុមនីយកម្ម ដើម្បីសម្រេចបាននូវគោលបំណងនៃ ESS5 របស់ WB ។
• ជំពូកទី៤ (វិសាលភាពនៃការអនុវត្ត គោលការណ៍ និងដំណើរការ) កំណត់វិសាលភាពដែល PRF អនុវត្តគោលការណ៍នៃសំណង ការគាំទ្រ ការដោះស្រាយផលប៉ះពាល់ និងការស្តារឡើងវិញនូវជីវភាពរស់នៅ ហើយពិពណ៌នាអំពីរបៀបដែលសំណង និងការដោះស្រាយផលប៉ះពាល់ត្រូវបានអនុវត្តជាដំណើរការមួយ។ ជាពិសេសជំពូកនេះពិពណ៌នាអំពីគោលការណ៍ និងដំណើរការនៃការធ្វើលទ្ធកម្មដីធ្លី/ការដោះស្រាយផលប៉ះពាល់ និងការបរិច្ចាគដោយស្ម័គ្រចិត្ត។ ក្របខ័ណ្ឌពិពណ៌នាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់សំណង និងសិទ្ធិទទួលបានការគាំទ្រ និងពិពណ៌នាអំពីសំណង និងគោលនយោបាយគាំទ្ររបស់គម្រោង។
• ជំពូកទី៥ (ការរៀបចំស្ថាប័ន និងការអនុវត្ត) កំណត់ភាគីពាក់ព័ន្ធសំខាន់ៗដែលទទួលខុសត្រូវក្នុងការអនុវត្តសំណង ការគាំទ្រ ការដោះស្រាយផលប៉ះពាល់ រួមទាំងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធសំខាន់ៗ ចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ។

• ជំពូកទី៧ (យន្តការដោះស្រាយបណ្ដឹងតវ៉ា) ពិពណ៌នាអំពីនីតិវិធីដោះស្រាយបណ្ដឹងតវ៉ា (GRM) របស់គម្រោងសម្រាប់បុគ្គល និងគ្រួសារដែលរងផលប៉ះពាល់ ដើម្បីប្រើប្រាស់ និងលើកឡើងពីកង្វល់របស់ពួកគេ ហើយត្រូវដោះស្រាយបណ្ដឹងតវ៉ារបស់ពួកគេតាមនីតិវិធីដែលបានពិពណ៌នា។ GRM របស់គម្រោងត្រូវបានរចនាឡើងដោយគិតគូរពីគោលការណ៍ នីតិវិធី និងការអនុវត្តបច្ចុប្បន្នសម្រាប់ការដោះស្រាយបណ្ដឹងតវ៉ា ស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ RGC និង ESS10 របស់ WB ស្ដីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការបង្ហាញព័ត៌មាន។

• ជំពូកទី៧ (ការរៀបចំការអនុវត្ត) កំណត់ពីរបៀបដែលថវិកាសម្រាប់ការអនុវត្តសំណង ការស្ដារជីវភាព ការគាំទ្រ និងការដោះស្រាយផលប៉ះពាល់ និងផែនការនៃការអនុវត្តដែលបានគ្រោងទុក (សម្រាប់ការធ្វើលទ្ធកម្មដីធ្លី និងការបរិច្ចាគដោយស្ម័គ្រចិត្ត) រួមទាំងការប៉ាន់ស្មានចំណាយ។

• ជំពូកទី៨ (ការបង្ហាញព័ត៌មាន និងការប្រឹក្សាភាគីពាក់ព័ន្ធ) ចែងអំពីដំណើរការនៃរបៀបដែលគោលនយោបាយសំណងត្រូវបានបង្ហាញដល់គ្រួសារដែលរងផលប៉ះពាល់ និងរបៀបដែលគ្រួសារដែលរងផលប៉ះពាល់ត្រូវបានចូលរួមនៅក្នុងដំណើរការនៃការពិគ្រោះយោបល់សម្រាប់ការបរិច្ចាគដោយស្ម័គ្រចិត្ត និងសម្រាប់ការធ្វើលទ្ធកម្មដីធ្លី។

• ជំពូកទី៩ (ការត្រួតពិនិត្យ និងការវាយតម្លៃ) ពិពណ៌នាអំពីរបៀបដែលការអនុវត្តផែនការដោះស្រាយផលប៉ះពាល់ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ។ នេះផ្ដល់នូវការណែនាំខ្លីៗអំពីរបៀបដែលការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្ត។

• ជំពូកទី១០ (ការចំណាយ និងថវិកា) រៀបរាប់យ៉ាងខ្លីអំពីការរៀបចំនៃការបែងចែកថវិកាសម្រាប់ការអនុវត្តផែនការដោះស្រាយផលប៉ះពាល់

• ឧបសម្ព័ន្ធនៃ RPF ផ្ដល់នូវការណែនាំ និងគំរូនៃការអនុវត្តបន្ថែមទៀត ជាពិសេសម៉ាទ្រីសទៅតាមលទ្ធភាព។